# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៣០ សសរ

## សេចក្តីសម្រេច

### ស្តីពីការបង្កើតគណៈកម្មការចំរុះ សំរាប់សិក្សា និងវាយតំលៃលើគំរោងវិនិយោគស្តារ និងអភិវឌ្ឍន៍ រមណីយដ្ឋានតំបន់ប្រាសាទបន្ទាយឆ្មារ-ប្រាសាទបន្ទាយតំព-ប្រាសាទឯកភ្នំ និងប្រាសាទភ្នំបាណន់ សំរាប់បំរើសំណូមពរវិនិយោគ របស់ក្រុមហ៊ុន SOKHA HOTEL CO., LTD.

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តនីតិច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទិ ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

- យោងស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៃក.អ.ក "គ.វ.ក" នាថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០២
- តាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ១:** បង្កើតគណៈកម្មការចំរុះ ដើម្បីសិក្សា និងវាយតំលៃលើគំរោងវិនិយោគស្ពា និងអភិវឌ្ឍន៍រមណីយដ្ឋាន តំបន់ប្រាសាទបន្ទាយឆ្មារ-ប្រាសាទបន្ទាយទ័ព ក្នុងខេត្តបន្ទាយមានជ័យ និងប្រាសាទឯកភ្នំ-ប្រាសាទភ្នំបាណន់ ក្នុងខេត្តបាត់ដំបង សំរាប់បំរើសំណូមពរវិនិយោគរបស់ក្រុមហ៊ុន SOKHA HOTEL CO., LTD. ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ឌី យ៉ាវ** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- | ឯកឧត្តម **គត់ វិបុល** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្តម **ជុច គឿន** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- | ឯកឧត្តម **ឈន អៀម** | រដ្ឋលេខាធិការ ក្រសួងធម្មការ និងកិច្ចការសាសនា | សមាជិក |
| ៥- | ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦- | ឯកឧត្តម **ស្នួន សិទ្ធី** | អគ្គលេខាធិការ គណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ៧- | ឯកឧត្តម **រស់ រ៉េន** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៨- | ឯកឧត្តម **ប្រាជ្ញ ស៊ុន** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៩- | ឯកឧត្តម **សេង លឹមនៅ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០- | ឯកឧត្តម **ថាច់ ឃន** | អភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ១១- | ឯកឧត្តម **ប្រាជ្ញ ចន្ទ** | អភិបាលខេត្តបាត់ដំបង | សមាជិក |
| ១២- | ឯកឧត្តម **នេព ហែន** | អគ្គនាយករងអាជ្ញាធរអប្សរា | សមាជិក |
| ១៣- | លោក **មុខ ម៉ិនហួន** | ប្រធាននាយកដ្ឋាន ក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា | លេខាធិការ |

សមាជិកគណៈកម្មការទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ២:** គណៈកម្មការនេះ មានភារកិច្ចដូចតទៅ :

ក- ចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាក់ស្តែងនូវបញ្ហាចំពោះមុខបច្ចុប្បន្ន អំពីផលដែលអាចនាំអោយមានការប្រែប្រួលបរិស្ថាន នៅតំបន់ប្រាសាទបន្ទាយឆ្មារ - ប្រាសាទបន្ទាយទ័ព - ប្រាសាទភ្នំបាណន់ និងប្រាសាទឯកភ្នំ ។

4L

ខ- សិក្សា និងវាយតំលៃលើទិដ្ឋភាពច្បាប់-បច្ចេកទេសពាក់ព័ន្ធដល់គំរោងវិនិយោគស្ពារ និងអភិវឌ្ឍន៍រមណីយដ្ឋានទាំង០៤ខាងលើ ដូចមានចែងក្នុងប្រការ១ ដើម្បីធ្វើជាមូលដ្ឋានសំរាប់ការពិនិត្យសំរេចក្នុងអង្គប្រជុំ"ច្រកចេញ-ចូលតែមួយ" លើសំណើសុំវិនិយោគរបស់ក្រុមហ៊ុន SOKHA HOTEL CO., LTD. នេះ នាពេលខាងមុខម្តងទៀត ។

ក្នុងករណីសំណើសុំវិនិយោគរបស់ក្រុមហ៊ុននេះ ត្រូវបានអនុញ្ញាតអោយវិនិយោគដោយមានការលើកទឹកចិត្តនោះ គណៈកម្មការនេះត្រូវមានភារកិច្ចបន្ត ដូចខាងក្រោម :

- រៀបចំបែបបទ ឯកសារគតិយុត្តិ - កំណត់ផែនការសកម្មភាព ព្រមទាំងរៀបចំប្លង់គោលអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ធម្មជាតិវប្បធម៌ទាំង០៤កន្លែង "តំបន់ប្រាសាទបន្ទាយឆ្មារ-ប្រាសាទបន្ទាយទ័ព - ប្រាសាទភ្នំបាណន់ និងប្រាសាទឯកភ្នំ" អោយបានច្បាស់លាស់ ដើម្បីធានាការគ្រប់គ្រង និងថែរក្សាតំបន់ប្រាសាទអោយបានល្អតាមលំនាំនៃព្រះរាជក្រឹត្យ ស្តីពីការបង្កើតរមណីយដ្ឋានភ្នំព្រះរាជទ្រព្យកន្លងមក
- តាមដានជាប្រចាំ នូវរាល់ការអនុវត្តការងាររបស់ក្រុមហ៊ុន តាមដំណាក់កាលនីមួយៗ
- លើកសំណើសុំការសំរេចពីរាជរដ្ឋាភិបាល ចំពោះករណីដែលហួសពីសមត្ថកិច្ចរបស់ខ្លួន
- រាយការណ៍អំពីលទ្ធផលការងារជាបន្តបន្ទាប់ជូនរាជរដ្ឋាភិបាល ។

**ប្រការ៣:** គណៈកម្មការនេះ មានការិយាល័យអចិន្ត្រៃយ៍តាំងនៅក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា ដោយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ ។

**ប្រការ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី- សហរដ្ឋមន្ត្រីក្រសួងក្រសួងមហាផ្ទៃ- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ- រដ្ឋមន្ត្រីក្រសួងទេសចរណ៍- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់- រដ្ឋមន្ត្រីក្រសួងបរិស្ថាន- រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា- ប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា- រដ្ឋមន្ត្រីគ្រប់ក្រសួង- ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤